**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង
# រវាង
# តំណាងកម្មករនិយោជិត និងសហជីពនៃសណ្ឋាគាររ៉ាហ្វលឡឺរ៉ូយ៉ាល់
# និង
# ក្រុមហ៊ុនសណ្ឋាគាររ៉ាហ្វិលរ៉ូយ៉ាល់

កិច្ចព្រមព្រៀងនេះត្រូវបានធ្វើឡើងនៅថ្ងៃ ទី៣១ ខែមីនា ឆ្នាំ២០២១ រវាងសហជីពនិយោជិតទេសចរណ៍អាស៊ាននៃសណ្ឋាគាររ៉ាហ្វលឡឺរ៉ូយ៉ាល់(ពីនេះតទៅហៅថា"សហជីព") និង ក្រុមហ៊ុនសណ្ឋាគាររ៉ាហ្វិល រ៉ូយ៉ាល់ (ពីនេះតទៅហៅថា "និយោជក")។ ភាគីនីមួយៗអាចហៅដោយឡែកថា "ភាគី" និងហៅជារួមថា "គូភាគី"។

សណ្ឋាគារ Raffles Hotel Le Royal កំពុងប្រឈមនឹងការលំបាកផ្នែកសេដ្ឋកិច្ចក្នុងកំឡុងពេលនៃជំងឺរាតត្បាតជាសកល COVID-19 ដែលមិនធ្លាប់មានពីមុនមក។ ការផ្ទុះឡើងនៃកូរ៉ូណាវីរុស ទូទាំងពិភពលោកបាននាំមកនូវ ការបញ្ឈប់ការធ្វើដំណើរអន្តរជាតិទាំងអស់ ហេតុដូចនេះហើយ សណ្ឋាគារកំពុងតែជួបប្រទះនូវកម្រិតអាជីវកម្មដែលមិនស្ថិតស្ថេរ។ ដូច្នេះ និយោជក និងសហជីពបានធ្វើការចរចា និងព្រមព្រៀងលើការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ៤៨នាក់ (ស្រី ១៣នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ២៤១នាក់ (ស្រី ៨៧នាក់) រយៈពេល ១៥ថ្ងៃ ដោយគិតចាប់ពីថ្ងៃ ទី១២ ខែមេសា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១។

ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារ គូភាគីបានព្រមព្រៀងគ្នាទទួលយកលក្ខខណ្ឌដូចខាងក្រោម៖

- ៧០% នៃប្រាក់ខែគោលសម្រាប់និយោជិកដែលទទួលបានប្រាក់ខែតិចជាង ៤០០ ដុល្លារ ក្នុងមួយខែ
- ៦៥% នៃប្រាក់ខែគោលសម្រាប់និយោជិកដែលទទួលបានប្រាក់ខែចន្លោះពី ៤០១ ដុល្លារ ទៅ ៤៨៦ ដុល្លារ ក្នុងមួយខែ
- ៦០% នៃប្រាក់ខែគោលសម្រាប់និយោជិកដែលទទួលបានប្រាក់ខែចន្លោះពី ៤៨៧ ដុល្លារ ទៅ ១.០០១ ដុល្លារ ក្នុងមួយខែ
- ៥០% នៃប្រាក់ខែគោលសម្រាប់និយោជិកដែលទទួលបានប្រាក់ខែច្រើនជាង ១.០០២ ដុល្លារ ក្នុងមួយខែ
- និយោជិកនឹងទទួលបានប្រាក់ធានានុគ្រោះ ៥០% នៃចំណែកក្នុងម្នាក់ដែលទទួល។
- រាល់អត្ថប្រយោជន៍ដែលមានស្រាប់នឹងបន្តធម្មតា
- អតីតភាពការងារនឹងមិនត្រូវបានប៉ះពាល់

ព្រះរាជាណាចក្រកម្ពុជា
Raffles Royal Hotel Pte., Ltd.

គូភាគីព្រមព្រៀងដោយផ្តិតមេដៃខាងក្រោមនេះ៖

ភាគី តំណាងកម្មករនិយោជិត និងសហជីព

ប៊ុន ឈឿន
ប្រធាន

ស៊ូ សោវ៉ុន
អនុប្រធាន

យស់ ចាន់ថុល
លេខាធិការ

ភាគីនិយោជក

រាជធានីភ្នំពេញ ថ្ងៃទី៣១ខែ សីហា ឆ្នាំ២០២១
ហត្ថលេខា និងត្រា
អ្នកគ្រប់គ្រងសណ្ឋាគារ

Raffles Royal Hotel Pte., Ltd.

Dennis de Groot